ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តកណ្តាល
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៧៣ ចុះថ្ងៃទី ២០
ខែ កក្កដា ឆ្នាំ ១៩៩៥
ជំនុំជំរះ
លេខ ៥២ ចុះថ្ងៃទី ១២
ខែ ធ្នូ ឆ្នាំ ១៩៩៥
សាលក្រម
លេខ ៥២ ព ចុះថ្ងៃទី ១២
ខែ ធ្នូ ឆ្នាំ ១៩៩៥

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការខេត្តកណ្តាល

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការខេត្តកណ្តាល នាថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៥ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**
លោក [redacted]
**តំណាងអយ្យការ**
លោក [redacted]
**ក្រឡាបញ្ជីសវនាការ**
លោក [redacted]

សាលក្រមនេះ បានចូលជាសាលក្រមស្ថាពរចាប់ពីថ្ងៃទី ៣០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦
តួភាគីពុំបានចូលមកប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
កណ្តាល.ថ្ងៃទី ៣០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦
ក្រឡាបញ្ជី
[redacted]
បានឃើញ
ប្រធានតុលាការ
[redacted]

**ដើម្បីជំនុំជំរះ :**

ឈ្មោះ **ខ អ** ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា សាសនាព្រះពុទ្ធ កើតនៅភូមិអណ្តូងពោរ ឃុំរលេង ស្រុកបារាយ ខេត្តកំពង់ធំ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិស្ពានថ្មី ឃុំកាកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល មុខរបរកងជីវពលឃុំ ។ ឪពុកឈ្មោះ ខ (រ) ម្តាយឈ្មោះ ម (ស) ប្រពន្ធឈ្មោះ **អ មណរ** មានកូន ០៤នាក់ (គេចខ្លួន) ។

ឈ្មោះនេះត្រូវចោទពីបទ : **រំលោភលើសិទ្ធិបុគ្គល** ប្រព្រឹត្តនៅភូមិស្ពានថ្មី ឃុំកាកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៥ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៧,៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

តាមរបាយការណ៍របស់នគរបាលខេត្តកណ្តាលលេខ ៥៦៨ រប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៥ និង យោងតាមដីកាសន្និដ្ឋានស្ថាពររបស់អយ្យការអមតុលាការខេត្តកណ្តាល លេខ ២៦៤ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :**

នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៥ វេលាម៉ោងប្រហែល ១៤:០០រសៀល ឈ្មោះ **ខ អ** បានចេញពីកន្លែងស៊ីផឹក ហើយត្រឡប់ទៅផ្ទះវិញ ដោយស្រវឹងខ្លាំងក្នុងដៃមានកាន់កាំភ្លើង AKស្វ័យមួយដើមដើរតាមបណ្តោយផ្លូវជាតិលេខ ៦A ប្រហែល



Scanned with CamScanner

ចម្ងាយ ៥០ម៉ែត្រ ស្របពេលជាមួយគ្នានោះមានរថយន្តមួយគ្រឿង បើកបរដោយឈ្មោះ **ល យយ** រួមដំណើរ ដោយឈ្មោះ **អសសត** ជាជនជាតិជប៉ុនមកដល់ទន្ទឹមនោះឈ្មោះ **ខ អ** បានបាញ់គំរាមកំហែងឡើងលើអោយ រថយន្តឈប់ ។ ពេលរថយន្តឈប់ហើយឈ្មោះ **ខ អ** ក៏ធ្វើដំណើរទៅមុខទៀតបានចម្ងាយប្រហែល ៥០ម៉ែត្រ ទើប ងាកក្រោយ ហើយបក់ដៃអោយរថយន្តបន្តដំណើរទៅមុខទៀតតែម្តង ឯឈ្មោះ **ខ អ** ក្រោយពេលកើតហេតុក៏គេច ខ្លួនបាត់រហូតដល់ពេលសព្វថ្ងៃ ។

-បានឃើញកំណត់ហេតុពិនិត្យកន្លែងកើតហេតុ របស់អធិការដ្ឋាននគរបាលស្រុកមុខកំពូល ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៥ បញ្ជាក់ថា កន្លែងកើតហេតុស្ថិតនៅលើផ្លូវជាតិលេខ ៦A បង្គោលគីឡូម៉ែត្រ ៣៧ ចន្លោះស្ពានលេខ ២២ និង ២៣ ក្នុងភូមិស្ពានថ្មី ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលនៅទីនោះពុំមានឃើញមានវត្ថុតាង និង ស្លាកស្នាមអ្វីដែលគួរអោយកត់សំគាល់ឡើយ ។

-បានឃើញលិខិតបញ្ជាក់សវិតាជាតិជនល្មើសរបស់មេឃុំរកាកោង២ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

-បានឃើញដីកាស្វែងរកចាប់ខ្លួនលេខ ១១៤ ដកសខ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥ របស់ចៅក្រម ស៊ើបអង្កេតតុលាការខេត្តកណ្តាល ។

-បានឃើញដីកាបញ្ជូនរឿងជំនុំជំរះលេខ ២៩១ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ចៅក្រមស៊ើប សួរ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ២២០ ដចត ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ ប្រធានតុលាការ ។

## <u>នាពេលសវនាការ</u>

ជនជាប់ចោទឈ្មោះ **ខ អ** រត់គេចខ្លួនគ្មានចម្លើយ ។

ជនរងគ្រោះឈ្មោះ **ល យយ** បានឆ្លើយថា ថ្ងៃកើតហេតុនោះ ខ្លួនបើករថយន្តដឹកលោក **អសសត** ពីភ្នំដិលមកការិយាល័យព្រែកលាប លុះបើកមកដល់ចំណុចចន្លោះស្ពានលេខ ២២ និង ២៣ ខ្លួនឃើញមនុស្សម្នាក់មិន ស្គាល់ឈ្មោះ ដោះអាវកាន់កាំភ្លើង AKស្ពាយ ដើរស្របទិសជាមួយរថយន្តខ្លួនដែរ ហើយពេលឡានខ្លួនបើកមកជិត ស្រាប់តែមនុស្សនោះបាញ់កាំភ្លើងកាត់មុខ និង ពីក្រោយឡាន ហើយឃាត់ឡានខ្លួនអោយឈប់ ពេលនោះជននោះ ស្រែកឡូឡាមិនអោយ ខ្លួនចុះពីលើឡាន រួចជននោះដើរទៅមុខឡានបានប្រហែល ៥០ម៉ែត្រ ក៏បាញ់ឡើងលើ ០២ទៅ ០៣គ្រាប់ទៀត ហើយជននោះដើរត្រឡប់មកឡានខ្លួនវិញ ហើយយកកាំភ្លើងរបស់គេចង្អុលធ្វើសញ្ញាអោយឡានខ្លួន បរចេញ ។ ពេលដែលជននោះភ្ជង់ និង បាញ់បង្ហើរលើឡានខ្លួននោះ ខ្លួនភ័យណាស់ ឯលោក **អសសត** ក៏ភ័យខ្លាំង ណាស់ដែរ ដោយគាត់អោនចុះស្របពូកឡាន ។ ខ្លួនសំណូមពរថ្ងៃក្រោយកុំអោយមានបញ្ហានេះទៀត ។

ជនរងគ្រោះឈ្មោះ **អសសត** ជនជាតិជប៉ុនបានឆ្លើយថា ខ្លួនជិះឡានជាមួយឈ្មោះ **ល យយ** ពីការ ដ្ឋានភ្នំដិលមកការិយាល័យព្រែកលាប ។ ពេលមកដល់ចំណុចចន្លោះស្ពានលេខ ២០ និង ២៣ ខ្លួនបានឃើញឡាន មួយឈប់ពីមុខឡានខ្លួន ហើយឡានខ្លួនឈប់ពីក្រោយឡាននោះ ដោយមានមនុស្សម្នាក់មិនដឹងជាប៉ូលីស ឬ អ្នក ស្រវឹងបានបាញ់ឡានដែលនៅពីមុខឡានខ្លួន តែបាញ់ឡើងលើ និង បាញ់បង្ហើរឡើងលើសំដៅឡានខ្លួន ០១គ្រាប់ តែគេនោះមិនបានហៅខ្លួនអោយចុះទេ រួចទើបអោយខ្លួនទៅ ។ នៅពេលដែលគេបាញ់នោះខ្លួនភ័យ និង ខ្លាចណាស់ ព្រោះកន្លងមកកម្មករម្នាក់ស្លាប់ដោយគេបាញ់នៅការដ្ឋាននេះដែរ ។ ខ្លួនសំណូមពរអោយតុលាការពង្រឹងសន្តិសុខដល់ អង្គភាពរបស់ខ្លួនផង ហើយរឿងនេះសូមច្បាប់សំរេចចុះ ។



Scanned with CamScanner

ថ្ងៃកើតហេតុខ្ញុំមិនចាំថ្ងៃខែ ក្រោយពេលដែលខ្ញុំ (តាមអំណានចម្លើយឈ្មោះ **ឃ ឈ** សាក្សីបំភ្លឺថា) ត្រឡប់ពីប្រជុំនៅស្រុកវិញឈ្មោះ **ម ទ** បានទៅផ្ទះខ្ញុំរាយការណ៍ប្រាប់ថា **ខ អ** ស្រវឹងស្រា ហើយបានឃាត់ឡានសុំលុយ ពេលនោះខ្ញុំថា បើដឹងថាស្រវឹងស្រាដែរ ម៉េចអោយវាកាន់កាំភ្លើង គាត់ថាពេលផឹកហើយខ្ញុំទៅផ្ទះមិនដឹងថា ធ្វើអញ្ចឹង លុះឮបាញ់ ទើបគាត់ត្រឡប់មកវិញ ឃើញ **ខ អ** ឈរឃាត់ឡានសុំលុយ ក្រោយពីឃាត់ **ខ អ** មិនស្តាប់ ទើបគាត់រាយការណ៍អោយខ្ញុំ ពេលនោះខ្ញុំបញ្ជាអោយគាត់ទៅដកអាវុធពី **ខ អ** ទុក លុះខ្ញុំទៅដល់កន្លែងកើតហេតុ **ម ទ** ប្រាប់ ថា ប្រពន្ធ **ខ អ** បានដកអាវុធពី **ខ អ** ស្រេចទៅហើយ ។ អាវុធ **ខ អ** ជាអាវុធធុន AK មានស្វ័យចំណុច ដែល **ខ អ** ធ្វើសកម្មភាពចន្លោះស្ពានលេខ២២ និង ២៣ តែកៀកស្ពានលេខ២២ ។

តាមអំណានចម្លើយឈ្មោះ **ម ទ** សាក្សីបំភ្លឺថា កាលពីថ្ងៃខែមិនចាំ ក្រោយពីឮផ្ទុះអាវុធខ្ញុំបានស្ទុះចេញពីផ្ទះដែលនៅឆ្ងាយពីកន្លែងកើតហេតុ ៣០០ម៉ែត្រ ដើរសំដៅមកកន្លែងកើតហេតុនៅស្ពានលេខ២២ ។ ពេលមកដល់ឃើញ ឈ្មោះ **ខ អ** កាន់កាំភ្លើង AK មានស្វ័យ ឃាត់ឡានទាំងនៅ និង មកប្រហែល ១០គ្រឿង ។ ពេលនោះ **ខ អ** បានគំរាមយកលុយបានជាង ០១ម៉ឺនរៀល ខ្ញុំបានអង្វរ **ខ អ** កុំអោយធ្វើអញ្ចឹង តែវាមិនស្តាប់ខ្ញុំខិតខំរកល្បិច ដើម្បីយកកាំភ្លើងពីដៃ **ខ អ** ដែរ តែវារករឿងចង់បាញ់ខ្ញុំទៀត ។ ពេលមានសកម្មភាព **ខ អ** កំពុងស្រវឹងស្រាខ្លាំង ពេលដែលខ្ញុំឃាត់ **ខ អ** មិនស្តាប់ ខ្ញុំក៏រត់ទៅរាយការណ៍ជូនលោកប្រធានសេនាជននៅផ្ទះគាត់ ពេលនោះគាត់មិនបានចុះទេ តែគាត់ថាអោយដកយកអាវុធពី **ខ អ** ខ្ញុំក៏ត្រឡប់មកវិញ ហើយយកអាវុធពីប្រពន្ធ **ខ អ** ព្រោះប្រពន្ធ **ខ អ** បានយកកាំភ្លើងពី **ខ អ** ស្រេចហើយ ។ ហើយព្រឹកឡើងក៏បាត់ **ខ អ** ពីផ្ទះរហូតមកដល់សព្វថ្ងៃ ។

នៅភូមិស្ពានថ្មី ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល ហើយសំរេចដីកាសន្និដ្ឋានស្ថាពរលេខ ២៦៤ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ **ខ អ** ពីបទរំលោភលើសិទ្ធិបុគ្គល កាលពីថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់អយ្យការទុកជាបានការពេញលេញ និង សំណូមពរផ្តន្ទាទោសតាមមាត្រា ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានស្តាប់ចម្លើយជនរងគ្រោះ
-បានស្តាប់ចម្លើយសាក្សី
-បានពិនិត្យភស្តុតាងនានា
-បានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

## តុលាការខេត្តកណ្តាល

## យល់ឃើញថា

-នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៥ នៅភូមិស្ពានថ្មី ឃុំរកាកោង២ ស្រុកមុខកំពូល ពិតជាមានបទល្មើសមួយ ដែលបង្កឡើងដោយឈ្មោះ **ខ អ** ទៅលើឈ្មោះ **អសសគ** ជាជនជាតិជប៉ុន និង លើឈ្មោះ **ឈ យយ** ជាជនជាតិខ្មែរប្រាកដមែន ។

-ឈ្មោះ **ខ អ** ជាសេនាជន ហើយជាអ្នកកាន់អាវុធគួរណាស់តែយកអាវុធនេះទៅប្រើប្រាស់តាមគោលការណ៍ដែលមេបញ្ជាការដាក់ចុះសំរាប់ការពារសន្តិសុខ និង សណ្តាប់ធ្នាប់ប្រជារាស្ត្រ តែផ្ទុយទៅវិញបែរជាឈ្មោះនេះអនុវត្តផ្ទុយយ៉ាងងងើល ដោយយកអាវុធដែលអង្គភាពបំពាក់អោយទៅប្រើប្រាស់ខុសគោលដៅ



Scanned with CamScanner

ដែលជាហេតុធ្វើអោយអាប់ឱនកិត្តិយសរបស់ប្រទេសជាតិ ដោយសារអំពើរបស់ខ្លួន ។

-ការប្រព្រឹត្តរបស់ឈ្មោះ ខ អ ដែលបានស្ទាក់ហៅរថយន្ត និងយកអាវុធទៅភ្ជង់បាញ់សំឡុតភ្នាក់ងារបរទេស និង ភ្នាក់ងារជាតិ ដែលកំពង់បំពេញការងារសាងសង់ផ្លូវជាតិលេខ ៦A នេះជាអំពើមួយពុំអាចអនុគ្រោះអោយបានឡើយ ។

-អំពើរបស់ជនជាប់ចោទរូបនេះ ធ្វើឡើងដោយស្មារតីទទួលខុសត្រូវគ្រប់គ្រាន់ ។

-ការប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ ខ អ នេះ ធ្វើប៉ះពាល់ដល់កិត្តិយសរបស់ប្រទេសជាតិ ប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ។

-អំពើរបស់ជនជាប់ចោទឈ្មោះ ខ អ នេះ ត្រូវផ្តន្ទាទោសតាមមាត្រា ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បើពិនិត្យលើអំពើរបស់ជនជាប់ចោទឈ្មោះ ខ អ ឃើញថា ពិតជាពុំអាចអនុគ្រោះអោយបានឡើយ ប៉ុន្តែបើពិនិត្យលើកត្តាសត្យានុម័តវិញឃើញថា ជនជាប់ចោទទើបប្រព្រឹត្តបទល្មើសជាលើកទី១ ហើយក្រោយពីប្រព្រឹត្តដឹងថាខុសក៏រត់គេចខ្លួនតែម្តង ។

-ជនរងគ្រោះឈ្មោះ **អសសត** និង ឈ្មោះ **ល យយ** ពុំបានប្តឹងទាមទារសំណងជម្ងឺចិត្តអ្វីទេ បញ្ហានេះតុលាការពុំលើកយកមកពិចារណាឡើយ ។

## ហេតុដូច្នេះសំរេច

១-ផ្តន្ទាទោស : ឈ្មោះ ខ អ (ឈ្មោះក្រៅគ្មាន) ភេទប្រុស អាយុ ៣៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ តែទោសនេះត្រូវព្យួរក្នុងរយៈពេលសាកល្បងចំនួន ០១ឆ្នាំគិតពីថ្ងៃសាលក្រមចូលជាស្ថាពរពីបទ រំលោភលើសិទ្ធិបុគ្គល កាលពីថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៥ នៅភូមិស្ពានថ្មី ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៥៧,៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

២-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនរងគ្រោះ កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់កំណត់ ១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹង ។ អោយជនជាប់ចោទប្តឹងទាស់ក្នុងរយៈពេល ១៥ថ្ងៃ និង ប្តឹងឧទ្ធរណ៍កំណត់ ០២ខែ គិតពីថ្ងៃផុតកំណត់ប្តឹងទាស់ ។

**ចៅក្រមជំនុំជំរះ**

[redacted]

---

ព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីអនុវត្តសាលក្រម ធ្វើយ៉ាងណាអោយសំរេចតាមសាលក្រមនេះ និង បង្គាប់អោយកងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ជួយផ្តល់កំលាំង ក្នុងការអនុវត្តសាលក្រមនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

*កណ្តាល, ថ្ងៃទី ៣០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦*

**បានឃើញ**
**ប្រធានតុលាការ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner